**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ស្ថានឯកអគ្គរាជទូតកម្ពុជា**
**ប្រចាំចក្រភពអង់គ្លេស**

ថ្ងៃព្រហស្បតិ៍ ២រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
ធ្វើនៅទីក្រុងឡុងដ៍ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

# លិខិតជូនពរ
# ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅចក្រភពអង់គ្លេស

ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសាកល ២០២១ ខាងមុខនេះ ខ្ញុំ និងភរិយា ព្រមទាំងមន្ត្រីការទូតទាំងអស់ នៅស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំចក្រភពអង់គ្លេស សូមជូនពរបងប្អូនប្រជាពលរដ្ឋខ្មែរទាំងអស់ ដែលកំពុងរស់នៅ និងធ្វើការ នៅក្នុងចក្រភពអង់គ្លេស សូមមានសុខភាពល្អបរិបូរណ៍ កម្លាំងកាយមាំមួន បញ្ញាញាណឈ្លាសវៃ ជន្មាយុយឺនយូរ ជៀសផុតពីជម្ងឺនានា ជាពិសេសជម្ងឺ កូវីដ-១៩ ដែលកំពុងឆ្លងរីករាលដាល និងរាតត្បាតពាសពេញពិភពលោក ។

សូមបងប្អូនទាំងអស់បន្តចូលរួមចំណែកយ៉ាងសកម្ម ក្នុងការប្រយុទ្ធប្រឆាំងទៅនឹងជម្ងឺកូវីដ-១៩ តាមរយៈការគោរពអនុវត្តឱ្យបានហ្មត់ចត់នូវបទបញ្ជារ និងវិធានការចាំបាច់នានា ដែលបានដាក់ចេញ ដោយរាជរដ្ឋាភិបាលចក្រភពអង់គ្លេស និងរាជរដ្ឋាភិបាលកម្ពុជា ក្នុងមនសិការ និងស្មារតីទទួលខុសត្រូវខ្ពស់បំផុត ។

ក្នុងឱកាសដ៏ប្រពៃថ្លៃថ្លានេះ ខ្ញុំសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យកែវទាំងបី និងវត្ថុស័ក្តិសិទ្ធទាំងអស់ក្នុងលោក សូមប្រោសប្រទានសព្វសាធុការពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរគ្រប់ប្រការ ជូនចំពោះបងប្អូនប្រជាជនខ្មែរទាំងអស់ ព្រមទាំងក្រុមគ្រួសារ សូមបានប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**ឯកអគ្គរាជទូត**

**ភាន់ ផារិទ្ធ**

64 Brondesbury Park, Willesden Green, London NW6 7AT, Tel: +44 20 8451 7850, Fax: +44 20 8451 7594
Email: cambodianembassy@btconnect.com Website: www.cambodianembassy.org.uk